ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ០៩១ ០៥ កសក

# ប្រកាស

## ស្តីពី

## បែបបទ និង សិទ្ធិសម្រេចពិន័យអន្តរការណ៍

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សម្រេច

**ប្រការ ១ :** ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ ត្រូវអនុវត្តដោយរដ្ឋបាលព្រៃឈើថ្នាក់មូលដ្ឋាន និង សម្រេចដោយរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ។

ការពិន័យអន្តរការណ៍អាចប្រព្រឹត្តបានចំពោះតែបទល្មើសព្រៃឈើមានចែងក្នុងមាត្រា ៩៦ នៃច្បាប់ស្តីពីព្រៃឈើ ដូចខាងក្រោម :

១- កាប់ដើមឈើដែលគ្មានស្លាកសញ្ញាសំគាល់អនុញ្ញាតឱ្យកាប់រំលំ ។

២- ដឹកជញ្ជូនផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

៣- ធ្វើសន្និធិផល អនុផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាត ។

៤- ដឹកជញ្ជូនផល អនុផលព្រៃឈើខុសទិសដៅ លើសបរិមាណកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។

៥- ប្រើប្រាស់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើហួសសុពលភាព ។

៦- មានយថាប្រភេទផល អនុផលព្រៃឈើខុសពីការកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។

៧- ធ្វើសន្និធិផល អនុផលព្រៃឈើលើសពីលិខិតអនុញ្ញាត ។

៨- នាំចេញផល អនុផលព្រៃឈើ គ្រាប់ពូជ និង ប្រភេទរុក្ខជាតិព្រៃ ដែលលើសពីការកំណត់ក្នុង អាជ្ញាប័ណ្ណ ។

៩- កាប់រំលំ អារ ច្រៀក និងចាំងឈើមូលក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ឬប្រើរណារយន្តជាមធ្យោបាយប្រមូលផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសញ្ញា ។

១០- ប្រមូលផល អនុផលព្រៃឈើក្រៅម៉ោងអនុញ្ញាត ។

១១- ដឹកជញ្ជូនផល អនុផលព្រៃឈើដែលកាប់រំលំ ឬប្រមូលយកមកដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១២- ផល អនុផលព្រៃឈើដែលយកមកកែច្នៃត្រូវបានកាប់ ឬប្រមូលដោយផ្ទុយនឹង បទប្បញ្ញត្តិនៃច្បាប់នេះ ។

១៣- ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលលក់ដូរ ចែកចាយ បានមកពីការកាប់ ឬ រុករក ដឹកជញ្ជូន កែច្នៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១៤- ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលបានមកពីការប្រមូលផល ដឹកជញ្ជូន កែច្នៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

១៥- នាំចេញផល អនុផលព្រៃឈើដែលអាជ្ញាប័ណ្ណគ្មានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ ។

១៦- ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមជិតផុតពូជ ។

១៧- យកធ្វើជាកម្មសិទ្ធ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬនាំចូលសត្វព្រៃរស់ និងសំណាកក្នុងក្រុមមានដោយកម្រ ។

១៨- ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមមានដោយកម្រ ។

១៩- ដឹកជញ្ជូន ធ្វើពាណិជ្ជកម្ម សន្និធិ កែច្នៃសំណាក ឬនាំចូលសត្វព្រៃរស់ និង សំណាកក្នុងក្រុមមានដោយបង្គួរ ដោយគ្មានលិខិតអនុញ្ញាត ។

២០- បរបាញ់ក្នុងទីសាធារណៈ ។

**ប្រការ ២ :** ដើម្បីពិន័យអន្តរការណ៍បាននៅពេលចាប់ឃាត់បទល្មើសព្រៃឈើជាក់ស្តែង លុះត្រាតែជនល្មើសសារភាពទោសកំហុសជាលាយលក្ខណ៍អក្សរជូនរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ដោយសុខចិត្តយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ស្របតាមទោសប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ ។

ក្នុងករណីជនល្មើសមិនព្រមសារភាពទោសកំហុស និងបង់ប្រាក់ពិន័យអន្តរការណ៍ រដ្ឋបាលព្រៃឈើត្រូវបញ្ជូនសំណុំរឿងបទល្មើសទៅតុលាការ ។

**ប្រការ ៣ :** ដើម្បីធានាប្រសិទ្ធិភាពនៃការអនុវត្តន៍ មាត្រា ៩១ និង មាត្រា ៩៦ នៃច្បាប់ស្តីពីព្រៃឈើ ក្នុងការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវពិចារណា លើកត្តា ដូចតទៅ :

- ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស
- ការខូចខាតដល់បរិស្ថាន និងការប៉ះពាល់សង្គម
- ចំនួននៃការប្រព្រឹត្តល្មើស
- បរិមាណប្រាក់ពិន័យដែលធ្វើឱ្យរាងចាល
- ការប្រព្រឹត្តល្មើសដោយចេតនា ។

**ប្រការ ៤ :** ជនល្មើសត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ជូនរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចនូវបរិមាណទឹកប្រាក់កំណត់តាមសេចក្តីសម្រេច ក្នុងរយៈពេលមិនលើសពីដប់ប្រាំ (១៥) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេច ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍តាមបរិមាណកំណត់ ឬផុតកាលកំណត់ រដ្ឋបាលព្រៃឈើត្រូវបញ្ជូនសំណុំរឿងចោទប្រកាន់ជនល្មើសទៅតុលាការ ។

**ប្រការ ៥ :** ក្រោយពេលជនល្មើសបង់ប្រាក់ពិន័យអន្តរការណ៍គ្រប់ចំនួន សាមីជនអាចរួចផុតពីការចោទប្រកាន់ទៅតុលាការ ។ វត្ថុតាងពិតប្រាកដនៃបទល្មើសត្រូវរឹបអូសជាសម្បត្តិរដ្ឋ និងអាចប្រគល់ឱ្យសាមីជនវិញនូវវត្ថុតាងផ្សេងទៀតក្រៅពីផល អនុផលព្រៃឈើដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសស្របតាមមាត្រា ៩៦ នៃច្បាប់ស្តីពីព្រៃឈើ ។

ជនល្មើសត្រូវទទួលបន្ទុកចេញសោហ៊ុយចំណាយជាក់ស្តែងក្នុងការលើកដាក់ ដឹកជញ្ជូន និង ថែរក្សាវត្ថុតាងទាំងអស់ ។

**ប្រការ ៦ :** ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និងប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

រដ្ឋមន្ត្រី

ចាន់-សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ